រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ:០១៩ ស/ណន.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីណែនាំ

## ស្តីពី

## ការសុំច្បាប់ឈប់ពិសេស របស់មន្ត្រីរាជការស៊ីវិល នៃក្រសួងមហាផ្ទៃ និងការសុំច្បាប់ឈប់សំរាក របស់មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ដែលឈរឈ្មោះជាបេក្ខជន បោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

* * *

យោងតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៦នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ។

យោងតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ២០០១ ។

យោងតាមបទបញ្ជា និងនីតិវិធី របស់ " គ.ជ.ប " សំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

ដើម្បីអនុវត្តបានត្រឹមត្រូវតាមវិធាន ដែលបានចែងក្នុងច្បាប់ បទបញ្ជា និងនីតិវិធីខាងលើនេះ ក្រសួងមហាផ្ទៃ សូមធ្វើការណែនាំអំពីបែបបទ និងនីតិវិធី សំរាប់ការសុំច្បាប់ឈប់ពិសេស របស់មន្ត្រីរាជការស៊ីវិល នៃក្រសួងមហាផ្ទៃ និងការសុំច្បាប់ឈប់សំរាក របស់មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ដែលឈរឈ្មោះជា បេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដូចខាងក្រោម :

### ក- ចំពោះមន្ត្រីរាជការស៊ីវិល នៃក្រសួងមហាផ្ទៃ

- មន្ត្រីរាជការស៊ីវិល នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលក្រសួងមហាផ្ទៃ ដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេសយ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោត រហូតដល់ថ្ងៃប្រកាសលទ្ធផល នៃការបោះឆ្នោតជាផ្លូវការ មកប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត ក្រុង សាមី ( នៅថ្នាក់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ ) និងមកសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ( នៅថ្នាក់កណ្តាល ) ។ ក្នុងរយៈពេលឈប់សំរាកពិសេសនេះ សាមីខ្លួនត្រូវបានរក្សាទុកប្រវត្តិ អតីតភាពការងារ សំរាប់ឡើងថ្នាក់ និងទទួលសោធននិវត្តន៍ ។

- ប្រសិនបើសាមីខ្លួនជាប់ឆ្នោត សាមីខ្លួនត្រូវធ្វើពាក្យសុំតាមឋានានុក្រមមកក្រសួងមហាផ្ទៃ ដើម្បីសុំទៅបំរើការងារនៅក្រៅក្របខ័ណ្ឌដើម ក្នុងរយៈពេលនៃអាណត្តិរបស់ខ្លួន ។ ក្នុងឋានៈនេះសាមីខ្លួន ត្រូវមានសិទ្ធិឡើងថ្នាក់ និងរក្សាអតីតភាពការងារ សំរាប់ទទួលសោធននិវត្តន៍ ។

- នៅពេលដែលចប់អាណត្តិ ជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឬនៅពេលលាឈប់ ឬឈប់បំពេញមុខងារ ជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ សាមីខ្លួនអាចស៊ើលត្រឡប់មកបំរើការងារនៅអង្គភាពដើមវិញ ។ ការចូលបំរើការងារនៅអង្គភាពដើមវិញ សាមីខ្លួនមានអាទិភាពទទួលកន្លែងទំនេរសមស្រប នឹងឋានន្តរស័ក្តិរបស់ខ្លួន ។

## ៦. ចំពោះមេឃុំ ចៅសង្កាត់ ជំទប់ និងចៅសង្កាត់រង

មេឃុំ ចៅសង្កាត់ ជំទប់ និងចៅសង្កាត់រង ដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ លើកទី១នេះ ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពីការងារ ទៅប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត ក្រុងសាមី តាមរយៈអភិបាលស្រុក ខណ្ឌសាមី ក្នុងរយៈពេលយ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោត រហូតដល់ថ្ងៃប្រកាសលទ្ធផលជាផ្លូវការ នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ របស់ខ្លួន រួចហើយសាមីខ្លួន ត្រូវវិលត្រឡប់មកកាន់មុខតំណែងវិញ ដើម្បីត្រៀមរៀបចំផ្ទេរ ប្រគល់ការងារជូនក្រុមប្រឹក្សាឃុំ សង្កាត់ថ្មី ។

ដើម្បីបន្តនិរន្តរភាពការងារឃុំ សង្កាត់ ក្នុងពេលដែលមេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រង សុំឈប់ពីមុខតំណែង ដើម្បីឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អភិបាលស្រុក ខណ្ឌសាមី ត្រូវជ្រើសរើសប្រជាពលរដ្ឋក្នុងឃុំ សង្កាត់នោះ ឬមន្ត្រីពីសាលាស្រុក ខណ្ឌរបស់ខ្លួន ឬមន្ត្រីឃុំ សង្កាត់ (មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ជំនួយការឃុំ សង្កាត់) ដែលមិនឈរឈ្មោះជាបេក្ខជន ស្នើទៅប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត ក្រុងសាមី ដើម្បីតែងតាំងបណ្តោះអាសន្នជាមេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រង ជំនួសមេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រង ដែលឈរឈ្មោះជាបេក្ខជន រហូតដល់ថ្ងៃប្រកាសលទ្ធផលជាផ្លូវការ នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ ការជ្រើសរើសតែងតាំងជាមេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រងនេះ ត្រូវជ្រើសយកអ្នកដែលមានលក្ខណៈសម្បត្តិ សមត្ថភាព និងបទពិសោធន៍ក្នុងការងារដឹកនាំ គ្រប់គ្រង ។

ការតែងតាំងបណ្តោះអាសន្នជាមេឃុំ ចៅសង្កាត់ ជំទប់ និងចៅសង្កាត់រង ត្រូវតែងតាំងដោយដីការបស់អភិបាលខេត្ត ក្រុងសាមី ហើយត្រូវធ្វើអោយបានស្របគ្នានឹងការអនុញ្ញាតច្បាប់ឈប់សំរាកជូនមេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រង ដែលឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

សាលាខេត្ត ក្រុងសាមីនីមួយៗ ត្រូវចាត់អោយស្រុក ខណ្ឌនីមួយៗ រៀបចំធ្វើពិធីប្រកាសផ្ទេរភារកិច្ចជូនមេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រង ដែលត្រូវតែងតាំងជំនួសបណ្តោះអាសន្ននោះ មួយថ្ងៃយ៉ាងយូរបន្ទាប់ពីចេញដីកាតែងតាំង ឬចេញច្បាប់អនុញ្ញាតអោយមេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រងទាំងនោះឈប់សំរាក ។ ក្នុងថ្ងៃប្រកាស ផ្ទេរភារកិច្ចបណ្តោះអាសន្ននេះ មេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រងទាំងនោះ ត្រូវធ្វើសេចក្តីរាយការណ៍អំពីការងារដែលខ្លួនកំពុងអនុវត្ត ការងារដែលនៅសេសសល់ បញ្ជីទ្រព្យសម្បត្តិ ប្រាក់កាស ...

និងឯកសារ លិខិតស្នាមនានា ដើម្បីផ្ទេរប្រគល់ អោយអ្នកមកជំនួស ។ អ្នកមកជំនួសមុខតំណែងជាមេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រង ក៏ត្រូវរៀបចំសេចក្តីរាយការណ៍ អំពីលទ្ធផលការងារដែលបានអនុវត្ត ការងារដែលនៅសេសសល់ បញ្ជីទ្រព្យសម្បត្តិ ប្រាក់កាស និងឯកសារ លិខិតស្នាមនានា ដើម្បីប្រគល់អោយមេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រង បន្ទាប់ពីថ្ងៃប្រកាសលទ្ធផលជាផ្លូវការ នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីអោយមេឃុំ ឬចៅសង្កាត់ រៀបចំរបាយការណ៍រួមរបស់ឃុំ សង្កាត់ ផ្ទេរប្រគល់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងកិច្ចប្រជុំលើកទី១ របស់ខ្លួន ។

## គ. ចំពោះមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ

មេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិ ដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពីការងារ មកអភិបាលស្រុក ខណ្ឌសាមី តាមរយៈមេឃុំ ឬចៅសង្កាត់សាមីយ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោត រហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ ។

ដើម្បីបន្តនិរន្តរភាពការងារតាមភូមិ ចំណុះឃុំ សង្កាត់នីមួយៗ ក្នុងពេលដែលមេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិ សុំច្បាប់ឈប់ពីការងារ ដើម្បីឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អភិបាលស្រុក ខណ្ឌសាមីត្រូវចាត់អោយមេឃុំ ឬចៅសង្កាត់ជ្រើសរើសអ្នកជំនួសមុខតំណែងជាមេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិ រហូតដល់ថ្ងៃប្រកាសលទ្ធផល នៃការបោះឆ្នោតជាផ្លូវការ ។ អ្នកជំនួស អាចជ្រើសយកប្រជាពលរដ្ឋ ដែលមានលក្ខណៈសម្បត្តិល្អ ក្នុងភូមិជាមួយ ឬអាចជ្រើសយកមន្ត្រីភូមិ (មេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិ) ក្នុងករណីដែលមន្ត្រីភូមិនោះមិនឈរឈ្មោះជាបេក្ខជនទាំងអស់គ្នា ។ ការតែងតាំងអ្នកមកជំនួសមុខតំណែងជាមេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិ ត្រូវធ្វើដោយដីការបស់សាលាស្រុក ខណ្ឌ ដោយត្រូវធ្វើអោយបាន ស្របគ្នានឹងការអនុញ្ញាតច្បាប់ឈប់សំរាកពីការងារ ។

បន្ទាប់ពីប្រកាសលទ្ធផលបោះឆ្នោតជាផ្លូវការ ប្រសិនបើមេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិ ជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ អ្នកដែលមកជំនួសមុខតំណែងខាងលើនេះ នឹងត្រូវទទួលបន្តតំណែងជាមេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិ រហូតដល់មានការជ្រើសតាំងជាថ្មីនូវមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ស្របតាមគោលការណ៍ ដូចមានចែងក្នុងមាត្រា៣០ និងមាត្រា៨៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

ក្នុងករណីដែលសាមីខ្លួន ជាមេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិ ដែលបានឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ មិនបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ សាមីត្រូវវិលមកកាន់មុខតំណែងរបស់ខ្លួនជាមេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិវិញ រហូតដល់មានការរៀបចំមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ស្របតាមគោលការណ៍ ដូចមានចែងក្នុង មាត្រា៣០ និងមាត្រា៨៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

ទទួលបានសេចក្តីណែនាំនេះ ក្រសួងមហាផ្ទៃ សង្ឃឹម និងជឿជាក់ថា ឯកឧត្តម ប្រតិភូរាជរដ្ឋាភិបាល ឯកឧត្តមនាយកខុទ្ទកាល័យ ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ឯកឧត្តមអគ្គាធិការ នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល ឯកឧត្តមអភិបាលគ្រប់ខេត្ត ក្រុង នឹងយកចិត្តទុកដាក់ផ្សព្វផ្សាយអនុវត្ត និងណែនាំដល់មន្ត្រីរាជការស៊ីវិល នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលក្រសួងមហាផ្ទៃ មេឃុំ ចៅសង្កាត់ ជំទប់ និងចៅសង្កាត់រង ដែលបានឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អោយដាក់ពាក្យសុំច្បាប់ឈប់សំរាកពិសេស និងសុំឈប់សំរាកពីមុខងារមកប្រធានអង្គភាពសាមីនីមួយៗ ដូចបានណែនាំខាងលើ អោយបានសំរេចទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០១

សហរដ្ឋមន្ត្រី

ស ខេង          យូ ហុកគ្រី

ចំលងជូន

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

( ជូនជ្រាបជាពត៌មាន )

- ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋាននគរបាលជាតិ អគ្គាធិការ នៃក្រសួងមហាផ្ទៃ
- គ្រប់សាលាខេត្ត ក្រុង

( ដើម្បីអនុវត្ត )

- ឯកសារ កាលប្បវត្តិ